ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Mar-2013, 11:30
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៩)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(19)

នៅចំពោះមុខ: **ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម Agnieszka KLONOWIECKA-MILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម យ៉ា ណារិន**

កាលបរិច្ឆេទ: **ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣**

ភាសា: **ខ្មែរ/អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ: **សាធារណៈ**

---

# ដីកាបង្គាប់ឱ្យអនុវត្តតាមៗតាមវិធាន ១០៨ នៃវិធានផ្ទៃក្នុង

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើម</u>**

**<u>ជនជាប់ចោទ</u>**

អៀង សារី
ខៀវ សំផន
នួន ជា

**<u>សហមេធាវីការពារក្តី អៀង សារី</u>**

**<u>បណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

អាង ឧត្តម

Michael KARNAVAS

**<u>សហមេធាវីការពារក្ដី នួន ជា</u>**

សុន អារុន

Victor KOPPE

**<u>សហមេធាវីការពារក្ដី ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSE
Arthur VERCKEN
Jacques VERGÈS

1. អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់ទោសឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង"អ.វ.ត.ក") ទទួលបានបណ្តឹងសាទុក្ខភ្លាមៗចំនួនបួន ដែល ដាក់ដោយ អៀង សារី និងបណ្តឹងសាទុក្ខមួយទៀតដាក់ដោយ នួន ជា ហើយនិងសំណើសុំមួយដែលដាក់ដោយ ខៀវ សំផន (ទាំងអស់នេះ"បន្ទុកការងារ")[1]។

2. ឯកសារខាងលើនេះ ត្រូវបានដាក់នៅចំពោះមុខក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោម តាមវិធាន ១០៦(២) នៃវិធានផ្ទៃក្នុង[2]។ យោងតាមវិធាន ១០៨(២) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ សាលាដំបូង តម្រូវឱ្យបញ្ជូន"សំណុំរឿង" ដោយរួមជាមួយនឹងច្បាប់ចម្លងត្រឹមត្រូវនៃសេចក្តីសម្រេច និងបណ្តឹង សាទុក្ខនីមួយៗមកដល់អង្គជំនុំជម្រះតុលាការកំពូល។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជាក់ស្តែង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានបញ្ជូនតែផ្នែកខ្លះនៃសំណុំរឿងបន្ទាប់ពីការដាក់បណ្តឹង សាទុក្ខទាំងនេះមក។ ជាឧទាហរណ៍ បន្ទាប់ពីការដាក់បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេច ផ្ទាល់ មាត់ស្តីពីការចូលរួមក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបាន បញ្ជូនបញ្ជី លេខឯកសារមួយដែលខ្លួនយល់ថាពាក់ព័ន្ធ ហើយអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលចូលមើល

---

[1] បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបដិសេធសិទ្ធិមានវត្តមាន ក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឱ្យថតវីដេអូក្នុងបន្ទប់ឃុំខ្លួនក្រោមសវនាការឯកសារលេខ E238/9/1/1, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ("បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់ស្តីពីការចូលរួមក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ"); បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើសុំចំណាត់ការបន្ទាប់អនុលោមតាមវិធាន ៣៥ ឯកសារលេខ E189/3/1/1, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២; បណ្តឹងសាទុក្ខរបស់អៀង សារី ប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គ ជំនុំជម្រះសាលាដំបូង ដែលថា គាត់ មានសមត្ថភាពគ្រប់គ្រាន់ចូលរួមសវនាការ និងការបដិសេធលើការតែងតាំង អ្នកជំនាញបន្ថែមដើម្បី វាយតម្លៃកាយសម្បទា ឯកសារលេខ E238/9/2/1, ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹង សេចក្តីសម្រេចស្តីពីកាយសម្បទា"); បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីទាក់ ទងទៅនឹងភាពមិនប្រក្រតីដែលបានចោទប្រកាន់ថា បានកើតមានក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការ (E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), ឯកសារលេខ E251/1/1, ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣; បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៣ ដែលបដិសេធសំណើសុំថតវីដេអូ និង/ឬសំលេងក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ឯកសារលេខ E254/3/1/1, ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("បណ្តឹសាទុក្ខ របស់ អៀង សារីប្រឆាំងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរស្តីពីការចូលរួមក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ"); *Demande de l'équipe de M. KHIEU Samphân tendant à ce que les ordonnances et décisions rendues par la Chambre de la Cour suprême lui soient notifiées dans les trois langues officielles des CETC*, ឯកសារលេខ E163/5/1/14, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[2] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក, វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។

តែឯកសារសម្ងាត់ ឬសម្ងាត់បំផុតណាដែលមាននៅក្នុងបញ្ជីនេះតែប៉ុណ្ណោះ[3]។ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនបញ្ជីឯកសារប្រហាក់ប្រហែលគ្នានេះ និងបានអនុញ្ញាតឱ្យចូលមើលឯកសារដែលខ្លួនយល់ថាពាក់ព័ន្ធទៅនឹងការដាក់នៃបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសម្បទា និងបណ្តឹងសាទុក្ខរបស់អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរស្តីពីការចូលរួមនៅក្នុងបន្ទប់ឃុំខ្លួនក្រោមសវនាការ[4]។

3. អំឡុងពេលទទួលបន្ទុកការងាររបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការចាំបាច់ក្នុងការពិនិត្យលើឯកសារសម្ងាត់ ឬសម្ងាត់បំផុតបន្ថែមទៀត ដែលមិនបានដាក់បញ្ចូលក្នុងផ្នែកខ្លះនៃសំណុំរឿងដែលបានបញ្ជូលមកនោះ ហើយ ដូច្នេះ ស្នើសុំក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបញ្ជូលបញ្ជីនៃឯកសារទាំងនោះ និងអនុញ្ញាតឱ្យចូលមើលបានដោយសមស្រប[5]។ ជាការឆ្លើយតប អង្គជំនុំជម្រះតុលាការកំពូលត្រូវបានបដិសេធក្នុងការផ្តល់ឯកសារ និងមិនឱ្យចូលមើលឯកសារដែលបានស្នើសុំ ដោយសំអាងថា វិធាន ១០៨ នៃវិធានផ្ទៃក្នុង "បែងចែកដាច់ពីគ្នារវាងបណ្តឹងសាទុក្ខលើសាលក្រម និងបណ្តឹងសាទុក្ខភ្លាមៗ" ដែលហាមឃាត់អង្គជំនុំជម្រះតុលាការកំពូលមិនឱ្យចូលមើលឯកសារណា ដែលមិនបានយោងនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗរបស់ភាគីឡើយ និងថា "បើផ្ទុយពីនេះ គឺមានន័យថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទទួលបានសំណុំរឿងទាំងមូលក្នុងពេលដំណាលគ្នា"[6]។

---

[3] អ៊ីម៉ែលរបស់លោក Roger PHILLIPS, ជាមន្ត្រីច្បាប់ និងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង, ចំណងជើងថា "ឯកសារសម្រាប់បណ្តឹងសាទុក្ខ E238/9/1/1", ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ នៅម៉ោង ១២ និង៥០ នាទី។

[4] អ៊ីម៉ែលរបស់លោក Roger PHILLIPS, ជាមន្ត្រីច្បាប់ និងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង, ចំណងជើងថា "បញ្ជីនៃឯកសារសម្រាប់បណ្តឹងសាទុក្ខ E238/9/2/1", ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣ វេលាម៉ោង ១៤ និង២១ នាទី។ អ៊ីម៉ែលរបស់លោក Roger PHILLIPS, ជាមន្ត្រីច្បាប់ និងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង, ចំណងជើងថា "Re: Fw: [Filed by Ieng Sary Def.] NEW DOCUMENT(S): CASE FILE No. 002 - IENG Sary - ការជូនដំណឹងរបស់អៀង សារី ស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីអៀង សារី សុំថតវីដេអូ ជាសំលេង និង/ឬរូបភាពលោក អៀង សារី ក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ និងសំណើសុំការបញ្ចូលគ្នានៃបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់ របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបដិសេធសិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ និងការហាមឃាត់មិនឱ្យថតវីដេអូក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការឯកសារលេខ (E238/9/1/1)" , ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ម៉ោង ១៦ និង ១៩ នាទី។

អ៊ីម៉ែលរបស់លោកស្រី Sheila PAYLAN, ជាមន្ត្រីច្បាប់ និងក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល, ចំណងជើងថា "សំណើសុំឯកសារបន្ថែមក្នុងសំណុំរឿង", ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ម៉ោង ១០ និង ៧ នាទី។

[6] អ៊ីម៉ែលរបស់លោក Roger PHILLIPS, ជាមន្ត្រីច្បាប់ និងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង, ចំណងជើងថា "Re: Fw: សំណើសុំឯកសារបន្ថែមលើសំណុំរឿង", ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣ ម៉ោង ០៩ និង ១៩ នាទី ("ជូន ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល អរគុណសម្រាប់ការស្នើសុំ ខ្ញុំយល់ស្របថា អង្គជំនុំជម្រះតុលាការកំពូល ទទួលបានសំណុំរឿងទាំងមូលបន្ទាប់ពីបណ្តឹងសាទុក្ខ

4. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយ ដើម្បីផ្អែកសម្រាប់ការបកស្រាយបែបនេះឡើយ។ ពាក្យថា "សំណុំរឿង" នៅក្នុងវិធាន ១០៨(២)នៃវិធានផ្ទៃក្នុង មិនបានកម្រិតដូច្នេះទេ ហើយពាក្យនេះត្រូវបានពន្យល់នៅក្នុងសន្ទានុក្រមនៃវិធានផ្ទៃក្នុង ដែលសំដៅទៅលើ "រាល់កំណត់ហេតុជាលាយលក្ខណ៍អក្សរ (*procès verbaux*) នៃកិច្ចស៊ើបអង្កេតដែលធ្វើឡើងក្នុងពេលស៊ើបអង្កេតបឋម ឬការស៊ើបអង្កេតតាមផ្លូវតុលាការ រួមទាំងរាល់សារណារបស់ភាគី សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ឯកសារភ្ជាប់ណាមួយ នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមបញ្ចូលទាំងកំណត់ហេតុកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះផង"[7]។ បន្ទាប់ពីការដាក់នូវបណ្តឹងសាទុក្ខណាមួយរបស់ភាគីក្នុងសំណុំរឿង ០០២ បង្ហាញថា ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវតែបញ្ជូន "សំណុំរឿង" ដូចដែលបានបញ្ជាក់។ ប្រសិនបើមាន ការកំណត់ថា ឯកសារអ្វីនៅក្នុងសំណុំរឿង មានការជាប់ពាក់ព័ន្ធទៅការជំនុំជម្រះត្រឹមត្រូវលើបណ្តឹងសាទុក្ខ ទោះជាភ្លាម និងលើសាលក្រមនោះ អាស្រ័យទៅលើឆន្ទានុសិទ្ធិតែម្នាក់របស់អង្គជំនុំជម្រះតុលាការកំពូល។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល តម្រូវចូលមើលឯកសារទាំងមូលក្នុងសំណុំរឿងដោយគ្មានការរិតត្បិតនៅក្នុងសំណុំរឿង ០០២ គ្រប់ពេលដែលខ្លួនទទួលបានបណ្តឹងសាទុក្ខភ្លាមៗ។

5. ពុំមានប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង ហាមឃាត់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មិនឱ្យទទួលសំណុំរឿងទាំងមូលក្នុងពេលដំណាលគ្នានោះឡើយ ឬក៏សំណុំរឿង ០០២ ដែលតាមនិយមន័យ គឺជាស្ថានភាពមួយដែលកើតមាននៅពេលដែលភាគីដាក់បណ្តឹងសាទុក្ខភ្លាមៗលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[8]។ ការបកស្រាយវិធាន ១០៨ នៃវិធានផ្ទៃក្នុង ដែលធ្វើឡើងដោយក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង មានកំហុស និងបណ្តាលឱ្យមានការពន្យារដែលមិនចាំបាច់ និងការលំបាកនៅក្នុងការទទួលនូវបន្ទុកការងាររបស់អង្គជំនុំជម្រះតុលាការកំពូល ជាពិសេស នៅពេលខ្លួនត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនទៅតាមកាលបរិច្ឆេទតឹងរ៉ឹង[9]។

---

លើសាលក្រម។ ប៉ុន្តែ វិធាន ១០៨ នៃវិធានផ្ទៃក្នុង *បែងចែកដាច់ពីគ្នារវាង បណ្តឹងសាទុក្ខលើសាលក្រម និងបណ្តឹងសាទុក្ខភ្លាមៗ* ។ ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗ ការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង គឺត្រូវផ្តល់ឯកសារទាំងឡាយនៅក្នុងសំណុំរឿង ដែលត្រូវបានយោងនៅក្នុងសារណារបស់ភាគី។ *ប្រសិនលើសពីនេះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទទួលបានសំណុំរឿងទាំងមូលក្នុងពេលដំណាលគ្នា*។ ហេតុនេះ ខ្ញុំមិនអាចអនុញ្ញាតឱ្យលោកស្រីចូលមើលឯកសារ សម្ងាត់ ឬសម្ងាត់បំផុត ដែលមិនបានយោងដោយភាគី នៅក្នុងបណ្តឹសាទុក្ខដែលលោកស្រីចងបាននោះឡើយ។ អរគុណសម្រាប់ការអធ្យាស្រ័យ" (សេចក្តីបញ្ជាក់បន្ថែម)។

[7] វិធានផ្ទៃក្នុង ទំព័រ ៧៩ (ភាសាអង់គ្លេស)។

[8] *សូមមើលខទា.* វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង ("លើកលែងតែមានប្បញ្ញត្តិណាចែងផ្ទុយនៅក្នុងវិធានផ្ទៃក្នុង ឬត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង បណ្តឹងសាទុក្ខមិនបានផ្អាកកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ")។

[9] *សូមមើល* វិធាន ១០៨(៤)(ស្ទួន) នៃវិធានផ្ទៃក្នុង។

6. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល:**

**បង្គាប់** អង្គជំនុំជម្រះសាលាដំបូងបញ្ជូនសំណុំរឿង ០០២ ទាំងមូល ជាបន្ទាន់មកអង្គជំនុំជម្រះតុលាការកំពូល ដោយអនុលោមតាមវិធាន ១០៨(២) នៃវិធានផ្ទៃក្នុង និង

**ណែនាំ** ផ្នែកគ្រប់គ្រងតុលាការនៃ អ.វ.ត.ក ជួយសម្រួលដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្ត **ដីកានេះ** ដោយអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលចូលមើលឯកសារទាំងអស់នៃសំណុំរឿង ០០២ ជាបន្ទាន់ និងដោយគ្មានការរិតត្បិត។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**